# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ អំពីការគោរពសិទ្ធិមនុស្សរបស់ព្រះពុទ្ធសាសនា មានការវៀរចាកជំនួញខុស៥ប្រការជាដើម ។

Website: www.hoksavann.org

ថ្ងៃទី២៥ ធ្នូ ២០០៤

ព្រះសម្ពុទ្ធជាកំពូលនៃអ្នកគោរពសិទ្ធិមនុស្ស ព្រោះលក្ខណៈនៃព្រះពុទ្ធមានព្រះទ័យបរិសុទ្ធផុតចាកការបៀតបៀនហើយ ទើបមានព្រះនាមថាវិសុទ្ធិគុណ ។ នៅក្នុងគម្ពីរព្រះត្រៃបិដក ដែលជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ដែលចាត់ជាធម៌និងវិន័យនោះ សុទ្ធតែជាពាក្យប្រៀនប្រដៅឲ្យលះបង់អំពើអាក្រក់គ្រប់យ៉ាង មានការបៀតបៀនអ្នកដទៃជាដើម សព្វបាបស្ស អករណំ ។ ព្រះអង្គគោរពសិទ្ធិមនុស្សផងណែនាំគេឲ្យគោរពផង ។ មិនត្រឹមតែគោរពសិទ្ធិមនុស្សទេ ព្រះអង្គឲ្យគោរពសិទ្ធិសត្វផង ដូចជាធម៌បាណាក្នុងសិក្ខាបទទី១នៃសីល៥ជាដើម ។ ធម៌ដែលព្រះអង្គណែនាំឲ្យគោរពសិទ្ធិមនុស្សមានចំនួនច្រើនណាស់ ពិសេសជំនួញ៥ប្រការ ដែលព្រះពុទ្ធហាមមិនឲ្យមនុស្សទូទៅជួញដូរឡើយ ។ ជំនួញ៥ប្រការនោះគឺ ជំនួញគ្រឿងសាស្ត្រាវុធ ជំនួញមនុស្ស សម្លាប់សត្វយកសាច់ធ្វើជំនួញ ជំនួញគ្រឿងស្រវឹង និងជំនួញថ្នាំពិស ។

១- សត្ថវណិជ្ជា ប្រែថាជំនួញគ្រឿងសាស្ត្រាវុធគ្រប់យ៉ាង ដូចជាកាំភ្លើងគ្រប់ធុនគ្រាប់បែកគ្រាប់យ៉ាងជាដើម ។ កាលជំនាន់ដើមមានត្រឹមតែធ្នូស្នា ក្រោយពេលវិទ្យាសាស្ត្រលូតលាស់ គឺលូតលាស់ទាំងសម្ភារៈល្អ ទាំងសម្ភារៈអាក្រក់ ។ ការបង្កើតសម្ភារៈល្អ សំរាប់សម្រួលជីវភាពការរស់នៅរបស់មនុស្សឲ្យបានខ្ពង់ខ្ពស់ល្អប្រសើរ ដូចជាថ្នាំពេទ្យទីលំនៅប្រដាប់ប្រដាប្រើប្រាស់ សំលៀកបំពាក់ ចំណីអាហារបរិភោគជាដើម

ការបង្កើតសម្ភារៈអាក្រក់ដែលធ្វើឲ្យអន្តរាយដល់សង្គម ដូចជាការបង្កើតកាំភ្លើងគ្រាប់បែក រហូតបង្កើតគ្រាប់បែកបរមាណូប្រល័យលោកជាដើម ។ ព្រះពុទ្ធហាមមិនឲ្យផលិត មិនឲ្យលក់ដូរគ្រឿងសាស្ត្រាវុធទាំងនោះ ព្រោះឲ្យនាំយកទៅសម្លាប់គ្នា ដោយមនុស្សគ្រប់រូបចង់រស់នៅក្នុងសុខសន្តិភាព មិនចង់ឲ្យអ្នកណាម្នាក់បៀតបៀនខ្លួនឡើយ ។ ការសម្លាប់គ្នា ឈ្មោះថាមិនគោរពជីវិតអ្នកដទៃ គឺពុំគោរពសិទ្ធិមនុស្សនេះឯង ។ ព្រះពុទ្ធសំដែងថា ខ្លួនមានសិទ្ធិចង់រស់ មនុស្សសត្វដទៃក៏ចង់រស់ដូចខ្លួនដែរ ដូច្នេះចូរកុំបៀតបៀនអ្នកដទៃ ។ នៅប្រទេសកម្ពុជា មានគ្រាប់កប់រាប់លានគ្រាប់ ពេលប៉ះវាផ្ទុះ ធ្វើឲ្យប្រជាពលរដ្ឋខ្មែររាប់ពាន់រាប់ម៉ឺននាក់ត្រូវស្លាប់និងពិការ កំបុតដៃកំបុតជើង នេះដោយសារការផលិត ការជួញការធ្វើសង្គ្រាម ដែលពិភពលោកប្រជុំគ្នាបំបាត់កុំឲ្យមាន ។

២- សត្តវណិជ្ជា សត្វក្នុងទីនេះសំដៅយកមនុស្ស គឺព្រះពុទ្ធហាមកុំឲ្យជួញប្តូរលក់មនុស្ស ។ ព្រះពុទ្ធសំដែងថា មនុស្សទោះបីមានឋានៈខ្ពស់ទាបយ៉ាងណាក៏ដោយ ក៏សុទ្ធតែមានតម្លៃខ្ពង់ខ្ពស់ពុំអាចកាត់ថ្លៃបានឡើយ ដូច្នេះចូរកុំបន្ថោកបន្ទាបតម្លៃរបស់មនុស្ស គឺកុំចាប់មនុស្សលក់ ។ កាលពីសម័យដើម មានការចាប់មនុស្សលក់ឲ្យទៅបំរើគេដាច់ថ្លៃ នេះហើយបានជាព្រះពុទ្ធហាមដោយព្រះបំណងមិនឲ្យកើតមានអំពើបែបនេះតទៅទៀត ។ នេះជាការរំលោភសិទ្ធិមនុស្ស ដែលមានជាតិជាមនុស្សដូចគ្នា ។ បច្ចុប្បន្ននេះ ពិភពលោកកំពុងតែដោះស្រាយបំបាត់អំពើអមនុស្សធម៌នេះ ដូចបញ្ហាបំបាត់ការចាប់ក្មេងស្រីលក់ឲ្យធ្វើជាស្រីពេស្យាជាដើម ។ ប្រទេសកម្ពុជាមានកើតបញ្ហានេះយ៉ាងខ្លាំងក្លា ដូចជាបញ្ឆោតស្រីខ្មែរទៅលក់ដូរនៅក្នុងប្រទេសនិងក្រៅប្រទេសឲ្យធ្វើជាស្រីពេស្យា ការរំលោភរបស់មនុស្សសាមញ្ញ ការរំលោភរបស់អ្នកមានអំណាចឲ្យស្រីខ្មែរបំរើខ្លួនក្នុងផ្លូវភេទ ក្នុងរូបភាពទិញដូរ ការរំលោភក្នុងរូបភាពទៅបំរើក្នុងគ្រួសារ ការរំលោភក្នុងរូបភាពបញ្ឆោតរៀបអាពាហ៍ពិពាហ៍ ការរំលោភក្នុងរូបភាពជួយរកការឲ្យធ្វើជាដើម ។ អំពើនេះកើតឡើងដោយសារភាពក្រីក្រ ភាពល្ងង់ខ្លៅ សីលធម៌ធ្លាក់ចុះ ប្រព័ន្ធច្បាប់ពុំតឹងតែង តុលាការពុករលួយ អ្នកកាន់អំណាចពុំមានសមត្ថភាព ។

៣- មំសវណិជ្ជា ជួញសាច់ គឺសម្លាប់សត្វធ្វើជំនួញ ។ នេះជាជំនួញដែលព្រះពុទ្ធហាម ជាសីលធម៌មានកម្រិតខ្ពស់របស់ព្រះពុទ្ធសាសនា ។ អ្នកដែកហ៊ានសម្លាប់មនុស្ស មកពីដំបូងរៀនសម្លាប់សត្វតិរច្ឆាន ។ ព្រះពុទ្ធបានបង្រៀនឲ្យពុទ្ធបរិស័ទរបស់ព្រះអង្គផ្សាយមេត្តាករុណាចំពោះសព្វសត្វក្នុងទិសទាំង១០ ។ មនុស្សនិងសត្វស្រឡាញ់ជីវិតដូចគ្នា ពុំមែនសត្វតិរច្ឆានណាមួយកើតឡើងសំរាប់ឲ្យគេសម្លាប់ធ្វើជាអាហារដូចជាសាសនាខ្លះពោលនោះឡើយ ។

៤- មជ្ជវណិជ្ជា កុំផលិតកុំជួញគ្រឿងស្រវឹងគ្រឿងញៀនគ្រប់ប្រភេទ ដូចស្រា អាភៀនជាដើម ព្រោះនាំឲ្យគេយកតៅផឹកទៅជក់នាំឲ្យអស់ទ្រព្យសម្បត្តិ នាំឲ្យកើតជម្លោះទាស់ទែងគ្នា នាំឲ្យកើតរោគ នាំឲ្យខូចសតិស្មារតី នាំឲ្យខូចការងារដែលត្រូវធ្វើ ។

៥- វិសវណិជ្ជា កុំផលិតកំជួញថ្នាំពិសថ្នាំពុល ព្រោះនាំឲ្យមនុស្សដែលមានអកុសលចិត្ត បានជាឧបករណ៍យកទៅបំពុលសម្លាប់គ្នា ជាការរំលោភសិទ្ធិមនុស្ស ។

បើមនុស្សគ្រប់រូបកុំជួញនូវជំនួញទាំង៥ប្រការនេះ នឹងធ្វើឲ្យពិភពលោកមានសន្តិភាព ជាការគោរពសិទ្ធិមនុស្សដល់ឫសគល់មានជម្រៅជាងសិទ្ធិមនុស្សដែលអង្គការសហប្រជាជាតិ បានប្រកាសកាលពីថ្ងៃ១០ធ្នូ១៩៤៨ទៅទៀត ។